KIDS LEGAL

*ការពារសិទ្ធិ និងធ្វើឱ្យការរស់នៅ*
*របស់កុមារនៅរដ្ឋ **Maine** មានភាពប្រសើរឡើង*

---

**KIDS LEGAL** គឺជាគម្រោងនៅទូទាំងរដ្ឋមួយនៅ Pine Tree Legal Assistance ។ យើងខ្ញុំមានជំនាញក្នុងសេវាកម្មផ្នែកច្បាប់ ដោយយកចិត្តទុកដាក់លើតម្រូវការរបស់កុមារ និងយុវជននៅរដ្ឋ Maine ដែលមានប្រាក់ចំណូលទាប ។ សេវាកម្មរបស់យើងខ្ញុំ ផ្តល់ជូនដោយឥតគិតថ្លៃ ។

**សេវាកម្មរបស់យើងខ្ញុំមាន :**

- **តំណាង**ឱ្យកុមារ និងយុវជនដោយផ្ទាល់ ឬ តាមរយៈអ្នកថែទាំរបស់ពួកគេ
- **ប្រឹក្សា**ជាមួយមេធាវី និងអ្នកផ្តល់សេវាកម្មក្នុងសហគមន៍ ពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារនៅក្នុង រដ្ឋ Maine
- **បណ្តុះបណ្តាល**ក្រុមការងារលើបញ្ហាច្បាប់ ដែលប៉ះពាល់ដល់កុមារ និងយុវជនដែលមានប្រាក់ចំណូលទាបនៅក្នុងរដ្ឋ Maine
- **សរសេរ**ឯកសារអប់រំអតិថិជនស្តីពីសិទ្ធយុវជននៅក្នុងរដ្ឋ Maine

**សំណុំរឿងដែលយើងខ្ញុំទទួលយក :**

- បញ្ហានៅសាលា រួមទាំងការអប់រំពិសេសផងដែរ
- បញ្ហាផ្នែកច្បាប់ ដែលប្រឈមមុខនឹងយុវជនដែលមិនត្រូវបានផ្តល់តម្លៃ
- អត្ថប្រយោជន៏សាធារណៈសម្រាប់អនីតិជន
- ការទទួលបានសេវាកម្មព្យាបាលដែលចាំបាច់
- បញ្ហាសុវត្ថិភាពនៅក្នុងបញ្ហាច្បាប់គ្រួសារមួយចំនួន
- ការងារការពារកុមារសម្រាប់យុវជនជនជាតិដើមអាមេរិក (Native American youth)

KIDS LEGAL ប្រើប្រាស់**វិធីសាស្ត្រពហុជំនាញ** ក្នុងការផ្តល់សេវាកម្មផ្នែកច្បាប់ឱ្យកុមារ និងយុវជនរបស់រដ្ឋ Maine ។ នេះមានន័យថា យើងខ្ញុំធ្វើការជាមួយអ្នកជំនាញមិនមែនផ្នែកច្បាប់ ដូចជា គ្រូពេទ្យ គ្រូបង្រៀន អ្នកចាត់ចែងសំណុំរឿង និងមនុស្សផ្សេងទៀត ដែលធ្វើការជាមួយអតិថិជនវ័យក្មេងរបស់យើងខ្ញុំផងដែរ ។ យើងខ្ញុំធ្វើដូចនេះដោយសារតែ យើងខ្ញុំជឿជាក់ថា វាគឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាពបំផុត ដើម្បីសម្រេចបាននូវទិន្នផលផ្នែកសុខភាព សុវត្ថិភាព អប់រំ និងសេដ្ឋកិច្ចបានកាន់តែប្រសើរសម្រាប់កុមារ ។

យុវជន និងអ្នកថែទាំរបស់ពួកគេ អាចទូរស័ព្ទមកយើងខ្ញុំដោយផ្ទាល់ ហើយយើងខ្ញុំក៏នឹងទទួលយកនូវការបញ្ជូនពីអ្នកផ្តល់សេវាកម្ម ដែលធ្វើការជាមួយយុវជនផងដែរ ។ នាពេលបច្ចុប្បន្ននេះ យើងខ្ញុំមានភាពជាដៃគូផ្នែកវេជ្ជសាស្ត្រ/ច្បាប់ជាមួយមន្ទីរពេទ្យ Barbara Bush Children’s Hospital នៅ Portland ហើយយើងខ្ញុំផ្តល់ជូនដល់ទីកន្លែងឱ្យមណ្ឌលយុវជនគ្មានជម្រកនៅ Bangor និង Portland ព្រមទាំងទៅឱ្យយុវជនជនជាតិភាគតិច Penobscot Nation ផងដែរ ។

**សូមមើលវិបសៃរបស់យើងខ្ញុំ : www.kidslegal.org**

- ព័ត៌មានអំពី KIDS LEGAL
- ប្រភពធនធានសម្រាប់កុមារ យុវជន ជំទង់ មាតាបិតា និងអ្នកផ្តល់សេវាកម្មក្នុងសហគមន៍ក្នុងរដ្ឋ Maine
- ព័ត៌មានផ្នែកច្បាប់ និងសិទ្ធិយុវជនក្នុងរដ្ឋ Maine

**ទាក់ទងយើងខ្ញុំតាម :** 1-866-624-7787 (ឥតគិតថ្លៃ)

| | |
|---|---|
| P.O. Box 547<br>88 Federal St.<br>Portland, ME | 61 Main St,<br>Room 41<br>Bangor, ME |
| 207-774-8246 | 207-942-8241 x217 |


**PTLA #499 (10/08)**